# ក្រុមមេធាវីការពារក្តី មាស មុត
# MEAS MUTH DEFENCE TEAM
# EQUIPE DE DEFENSE DE MEAS MUTH

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2014, 12:48
CMS/CFO: Sann Rada

**អាង ឧត្តម និង** Michael G. KARNAVAS
សហមេធាវីការពារក្តីលោក មាស មុត
ថ្ងៃទី ៥ ខែធ្នូ ឆ្នាំ ២០១៤

<u>គោរពជូន</u>៖ លោកចៅក្រម **យូ ប៊ុនឡេង**
លោកចៅក្រម Mark HARMON
សហចៅក្រមស៊ើបអង្កេត

<u>កម្មវត្ថុ</u>៖ សេចក្តីជូនដំណឹងទាក់ទងនឹងការចូលរួមក្នុងការបង្ហាញខ្លួនបឋម ដែលគ្រោងធ្វើនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤

សូមគោរពជូនចំពោះលោកសហចៅក្រមស៊ើបអង្កេត៖

នៅថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ យើងខ្ញុំបានទទួលលិខិតមួយច្បាប់ពីលោកចៅក្រម ដែលថ្លែង *ទៅក្នុងចំណោមនោះ* (inter alia) ថា យើងខ្ញុំ "ទាំងពីររូបជាប់កាតព្វកិច្ចអនុវត្តតាមដីកាកោះហៅមេធាវី ហើយ [គឺ] ត្រូវបានរំពឹងទុកថានឹងបង្ហាញខ្លួននៅចំពោះមុខ [លោកចៅក្រម] នៅវេលាម៉ោង ១ រសៀល នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤"[1]។

យើងខ្ញុំមិនដែលមានចេតនាមិនគោរពតាមដីកាកោះរបស់លោកចៅក្រមឡើយ ទោះបីជា យើងខ្ញុំមានការលំបាកក្នុងការបង្ហាញខ្លួននៅចំពោះមុខលោកចៅក្រមក៏ដោយ ដោយហេតុថា យើងខ្ញុំមិនមានការបង្គាប់ណាមួយពីសំណាក់កូនក្តីរបស់យើងខ្ញុំឡើយ ហើយប្រាកដណាស់ យើងខ្ញុំមិនមានគោលជំហរប្រាប់ឱ្យគេដឹងអំពីការប្រាស្រ័យទាក់ទងណាមួយរវាង មេធាវី-កូនក្តី ឡើយ។

តាមរយៈនេះ យើងខ្ញុំសូមគោរពជូនដំណឹងលោកចៅក្រម មេត្តាជ្រាបថា លោក Karnavas មានបំណងឱ្យលើកលែងផុតពីការចូលរួមនៅក្នុងការបង្ហាញខ្លួនបឋម។ យើងខ្ញុំបានទទួលដីកាកោះហៅមេធាវីក្នុងរយៈពេលមួយថ្ងៃមុនពេលដែលលោក Karnavas គ្រោងចាកចេញពីរាជធានីភ្នំពេញ។ ដោយសារតែ

[1] ចម្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៤ ចុះថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០១៤ ឯកសារ A67/1/1។

មានកិច្ចការដទៃទៀតដែលបានគ្រោងធ្វើពីមុនរួចមកហើយ វានឹងជាការលំបាកសម្រាប់លោក Karnavas ក្នុងការត្រឡប់មករាជធានីភ្នំពេញវិញឲ្យទាន់នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០១៤។ ទោះបីជាយ៉ាងនេះក្តី ប្រសិនបើវត្តមានរបស់លោក Karnavas ត្រូវបានចាត់ទុកថាជាការចាំបាច់ ហើយប្រសិនបើគាត់ត្រូវបានបង្គាប់ឲ្យបង្ហាញខ្លួន ថ្វីបើកូនក្តីរបស់យើងខ្ញុំមានចេតនាមិនគោរពតាមដីកាកោះក្តី លោក Karnavas នឹងធ្វើការរៀបចំចាំបាច់នានា ដើម្បីបង្ហាញខ្លួនតាមដែលគ្រោងទុក។

ប្រសិនបើ លោក Karnavas ត្រូវបានលើកលែងឲ្យរួចផុតពីការចូលរួម យើងខ្ញុំសូមគោរពស្នើសុំថា អ្នកស្រី Tanya Pettay ដែលជាអ្នកប្រឹក្សាច្បាប់ជាន់ខ្ពស់របស់យើងខ្ញុំ ចូលរួមជំនួសលោក Karnavas ដើម្បីជាជំនួយដល់លោក អាង ឧត្តម។

សូមលោកចៅក្រមមេត្តាទទួលយកលិខិតនេះដោយក្តីគោរពអំពីយើងខ្ញុំ។

សហមេធាវីរបស់ មាស មុត

អាង ឧត្តម **Michael G. KARNAVAS**